ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០.៧.០.២........អ.ក.ស/ទ.អ.ម.ស

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០០៩...

រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

ជំរាបមក

លោក លោកស្រី ប្រធានគ្រឹះស្ថានអាហារីណ នីហរ័ណឱសថ

លោក លោកស្រី ប្រធានគ្រឹះស្ថានផលិតឱសថ

**កម្មវត្ថុ** : ការហាមនាំចូល ឬផលិតឱសថដែលមានការវេចខ្ចប់សំរាប់ផ្គត់ផ្គង់មន្ទីរពេទ្យ ចែកចាយដល់ឱសថស្ថាន ឱសថស្ថានរង និងសេវាសុខាភិបាលឯកជន ។

ដើម្បីទប់ស្កាត់ការលក់ឱសថរដ្ឋនៅតាមឱសថស្ថាន ឱសថស្ថានរង សេវាសុខាភិបាលឯកជន និង ដើម្បីឱ្យអ្នកប្រើប្រាស់ងាយស្រួលក្នុងការទុកដាក់ ជៀសវាងការច្រឡំឱសថ ក្រសួងសុខាភិបាលមិនអនុញ្ញាតឱ្យបណ្តាគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ គ្រឹះស្ថានផលិតឱសថទាំងអស់ នាំចូល ឬ ផលិតឱសថដែលមានការវេចខ្ចប់ជាកំប៉ុងច្រើនជាង ១០០គ្រាប់ ឬ ឱសថជាថ្នាំទឹកសំរាប់ផឹកច្រកជាដបដែលមានចំណុះច្រើនជាង ៣០០មល សំរាប់ចែកចាយដល់ឱសថស្ថាន ឱសថស្ថានរង សេវាសុខាភិបាលឯកជនទៀតឡើយ លើកលែងតែការនាំចូល ឬការផលិតនោះសំរាប់ផ្គត់ផ្គង់ប្រព័ន្ធសុខាភិបាលសាធារណៈ ។

ក្រសួងសុខាភិបាលសង្ឃឹមថា លោក លោកស្រីប្រធានគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ គ្រឹះស្ថានផលិតឱសថទាំងអស់ នឹងអនុវត្តតាមការណែនាំខាងលើជាមិនខាន ។

សូមលោក លោកស្រី ប្រធានទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ឱសថការី ជូ យិនស៊ីម

**ចម្លងជូន :**

- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- គ្រប់មន្ទីរសុខាភិបាលរាជធានី ខេត្ត
- កាលប្បវត្តិ
- ឯកសារ

569